ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
Ministry of Agriculture Forestry and Fisheries
គម្រោងពិពិធកម្មកសិកម្មកម្ពុជា
Cambodia Agricultural Sector Diversification Project
World Bank Loan No .IDA Credit 6366-KH

# សេចក្តីជូនដំណឹង
# ស្តីពីការជ្រើសរើសអ្នកបើកបរ

អង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា(CASDP) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវការជ្រើសរើសអ្នកបើកបររថយន្តចំនួន០៥នាក់ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

-ត្រូវមានអាយុចាប់ពី១៨ឆ្នាំ ដល់៥០ឆ្នាំ និងមានប័ណ្ណបើកបរត្រឹមត្រូវស្របតាមច្បាប់កំណត់
-មានបទពិសោធន៍បើកបរយ៉ាងតិច ០៣ឆ្នាំ
- មានភាពស្មោះត្រង់ និងមិនធ្លាប់មានទោស ឬជាប់ពិរុទ្ធជន
-មានសុខភាពល្អ និងអនាម័យក្នុងការរស់នៅល្អ
-មានភាពឯករាជ្យក្នុងការងារ ជាអ្នកឧស្សាហ៍ព្យាយាម និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងារ
-មានពេលវេលាគ្រប់គ្រាន់ក្នុងការចុះបំពេញការងារតាមបណ្តាខេត្តនានា
-ចេះអាន និងសរសេរភាសាអង់គ្លេសបានកាន់តែប្រសើរ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមទំនាក់ទំនងជាមួយផ្នែករដ្ឋបាលនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីទទួលព័ត៌មានពាក់ព័ន្ធបន្ថែម និងបំពេញបែបបទសំណុំឯកសារសម្រាប់ការដាក់ពាក្យស្នើសុំសម្រាប់ការជ្រើសរើស ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប មានបិទរូបថតទំហំ ៤x៦ រួមទាំងឯកសារច្បាប់ចម្លង៖

-អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ និងបណ្ណបើកបរ
-ឯកសារពាក់ព័ន្ធបទពិសោធន៍ការងារ។

សំណុំឯកសារដាក់ពាក្យដែលបានបំពេញរួច សូមផ្ញើមក ឬ ដាក់នៅផ្នែករដ្ឋបាលនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (អង្គភាពសម្របសម្រួលគម្រោងCASDP, អគារនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជាន់ផ្ទាល់ដី) យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៥:០០ ល្ងាចជាកំហិត ។

**បញ្ជាក់៖** បេក្ខជនមានលក្ខណៈសម្បត្តិសមស្រប នឹងត្រូវបានសម្រិតសម្រាំង និងទទួលបានអញ្ជើញធ្វើការសម្ភាសន៍ស្ទាបស្ទង់សមត្ថភាពមុននឹងត្រូវបានសម្រេចឱ្យចូលបម្រើការងារ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

**ជ.នាយកគម្រោង**
**ប្រធានគ្រប់គ្រងគម្រោង**